# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 535

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : របៀងអភិរក្សជីវៈចម្រុះមហា អនុតំបន់ មេគង្គ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 23/03/11 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/03/19 |
| ៣. ចំណាយគម្រោងសរុប | $13,070,000 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងបរិស្ថាន |
| RESPONSIBLE UNIT | Ministry of Environment |
| អង្គភាពទទួលខុសត្រូវ | ក្រសួងបរិស្ថាន |
| ៥. ស្ថានភាពគម្រោង | គម្រោងដែលបានបញ្ចប់ |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងជំនួយបច្ចេកទេស |
| ៧. ប្រភពហិរញ្ញប្បទាន៖ | ជំនួយឥតសំណង |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី១- ការអភិវឌ្ឍវិស័យកសិកម្ម

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពនៅក្នុងតំបន់ការពារធម្មជាតិតាមរយៈសកម្មភាពរួមបញ្ចូលគ្នារវាងការ អភិរក្ស និងការអភិវឌ្ឍន៍

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

បរិស្ថាន និងការអភិរក្ស

Environment and Conservation, excluding Forestry Sector

Environment and Conservation, excluding Forestry Sector

Environment and Conservation, excluding Forestry Sector

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

មណ្ឌលគីរី, កោះកុង,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គឺដើម្បីពង្រឹងសហគមន៍ និងស្ថាប័ន ស្តារ ការពារ និងថែរក្សារបៀងជីវៈចម្រុះ និងដើម្បីលើកកម្ពស់ជីវភាព និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចដល់ប្រជាសហគមន៍ដែលពឹងផ្អែកលើធនធានធម្មជាតិ

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

ផ្នែកពង្រឹងសហគមន៍ និងស្ថាប័នមានលទ្ធផលរំពឹងទុកចំនួន៩ ដែលរួមមាន៖

(១) ត្រឹមឆ្នាំ២០១៧ កំណត់តំបន់របៀងជីវៈចម្រុះឲ្យបាន៣៥០ ០០០ហិកតា

(២) ត្រឹមឆ្នាំ២០១៨ ក្រសួងបរិស្ថាននឹងអនុម័តផែនការសកម្មភាពនៃគោលបំណងយុទ្ធសាស្ត្រទី៣ នៃផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ

(៣) ត្រឹមឆ្នាំ២០១៨ ក្រសួងបរិស្ថាននឹងអនុម័តគោលការណ៍ណែនាំសម្រាប់គ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ

(៤) កំណត់ព្រំប្រទល់សហគមន៍ ៩កន្លែង

(៥) ត្រឹមឆ្នាំ២០១៨ អនុម័តកិច្ចព្រមព្រៀងសហគមន៍

(៦) ឲ្យស្ត្រីចូលរួមសកម្មភាពទាំងនេះឲ្យបាន៣០%

(៧) បណ្តុះបណ្តាលមន្ត្រីថ្នាក់ជាតិឲ្យបាន ៣០រូប ថ្នាក់ខេត្ត ១០០រូប ថ្នាក់ឃុំ ២០០ និងថ្នាក់ភូមិឲ្យបាន១ ១០០រូប

(៨) អ្នកបណ្តុះបណ្តាលត្រូវមានសមាសភាពជាស្ត្រី ៤០% (៩) ជនជាតិដើមភាគតិចចូលរួមក្នុងសកម្មភាពនេះ

ថែរក្សាការពារ និងស្តារ របៀងជីវៈចម្រុះមានលទ្ធផលរំពឹងទុកចំនួន៤ រួមមាន៖

(១) ដើរល្បាត

(២) រៀបចំថ្នាល

(៣) ដាំស្តារឲ្យបាន១,២៧៥ ហិកតា

(៤) កសិរុក្ខកម្មឲ្យបាន ៣០០ហិកតា និងលើកកម្ពស់ជីវភាព និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

លទ្ធផល៣៖ លើកកំពស់ជីវភាពនិងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

(១) យ៉ាងតិច៤៥០គ្រួសារចូលរួមអនុវត្តគម្រោងកសិកម្ម

(២) ១០០មេគ្រួសារជាស្ត្រីនឹងចូលរួមគម្រោងកែលម្អជីវភាព

(៣)ត្រឹមឆ្នាំ២០១៨ យ៉ាងហោចណាស់ខ្សែចង្វាក់ផលិតកម្មវិនិយោគ៤បានបង្កើត និងអនុវត្ត

(៤) ត្រឹមឆ្នាំ២០១៦ យ៉ាងហោចណាស់មានក្រុមសន្សំប្រាក់ចំនួន ១៨ក្រុមបានបង្កើត

(៥) យ៉ាងហោចណាស់៥០%នៃសមាជិកក្រុមសន្សំជាស្ត្រី

(៦)ត្រឹមឆ្នាំ២០១៨គម្រោងវិនិយោគផ្នែកកែលម្អជីវភាព និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចបានបញ្ចប់។

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

**គម្រោងនេះជាប្រភេទគម្រោងដែលបញ្ចូលការអភិរក្ស និងការអភិវឌ្ឍន៍ដែលបានផ្តល់ជម្រើសសកម្មភាពជីវភាព ជាច្រើនដែលបានមកពីការអភិរក្ស និងការអភិវឌ្ឍន៍**

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

**ប្រជាសហគមន៍ ដែលអាស្រ័យផលទៅលើធនធានធម្មជាតិ និងអនុវត្តកសិរុក្ខកម្ម នៅតំបន់ការពារធម្មជាតិចំនួន៩ សហគមន៍ទទួលផលដោយផ្ទាល់អំពីគម្រោងនេះ ហើយគម្រោងក៏ជួយស្តារ ការពារ និងថែរក្សានូវជីវៈចម្រុះនៅ សហគមន៍ទាំងនោះផងដែរ។**

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | **មាន** |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **ត្រូវបានបញ្ចប់** |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**កន្លងមកគម្រោងមិនមានផលប៉ះពាល់ដល់ផ្នែកបរិស្ថាន និងសង្គមនោះទេ ហើយគម្រោងក៏មានអ្នកជំនាញក្នុងការ ផ្តល់យោបល់ដើម្បីជៀសវាងផលប៉ះពាល់ផលប៉ះពាល់ដល់ផ្នែកបរិស្ថាន និងសង្គម។ សកម្មភាពភាគច្រើនអនុវត្តដោយ ប្រជាសហគមន៍ ហើយគម្រោងក៏មានសកម្មភាពសម្រាប់លើកកម្ពស់ជីវភាព និងហេដ្ឋារចនាសម្ព័ន្ធផងដែរ ដូច្នេះ គម្រោងនេះជួយគាំទ្រយ៉ាងខ្លាំងដល់ការលើកកម្ពស់និងកាត់បន្ថយភាពក្រីក្រដល់ប្រជាសហគមន៍។**

**១៩. ការប្រែប្រួល អាកាសធាតុ**

| | |
|---|---|
| ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? | **មាន** |
| ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស | **ការបន្សុាំ** |

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែល ទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

| | |
|---|---|
| តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? | **គ្មាន** |

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**លទ្ធផលរំពឹងទុករបស់គម្រោងនេះសំខាន់គឺជម្រុញឲ្យបាន៣០% នៃគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិគឺជាស្ត្រី ហើយយ៉ាងតិចណាស់ឲ្យបាន៤០% ជាស្ត្រីត្រូវបានចូលរួមនូវសកម្មភាពនានារបស់គម្រោង ពិសេសចូលរួមវគ្គបណ្តុះបណ្តាល។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

មន្ត្រីក្រសួងបរិស្ថានមានមន្ត្រីដែលមានសមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការអនុវត្តលទ្ធផលទី១ និងលទ្ធផលទី២

២៣. [illegible] របស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាល ឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

ផ្នែកពង្រឹងសហគមន៍ និងស្ថាប័ន និងផ្នែកស្តារ ការពារ និងថែរក្សារបៀងជីវៈចម្រុះបានអនុវត្តដោយរលូន ប៉ុន្តែផ្នែកលើកកម្ពស់ជីវភាពមានភាពយឺតយ៉ាវដោយសារតែក្រុមហ៊ុនអនុវត្តមិនបានអនុវត្តដោយខ្លួនឯង។

២៤. **អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

5

២៥. **ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

ធនាគារអភិវឌ្ឍន៍អាស៊ីគឺជាម្ចាស់ជំនួយដែលគាំទ្រការអនុវត្តគម្រោងនាពេលបច្ចុប្បន្ន ហើយសក្តានុពលនៃម្ចាស់ជំនួយនាពេលអនាគតរួមមាន៖ ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និងUSAID

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2018 | | 2019 | 2020 | 2021 | 2022 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2020-2022 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 993.0 | 0.0 | 413.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 6.4 | 0.0 | 11.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 121.3 | 0.0 | 50.7 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 865.3 | 0.0 | 350.8 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 5,196.8 | 0.0 | 1,920.8 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 100.0 | 0.0 | 638.4 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 3,207.1 | 0.0 | 1,042.8 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 48.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 407.3 | 0.0 | 37.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 1,434.4 | 0.0 | 202.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 6,189.8 | 0.0 | 2,333.9 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2018 | | 2019 | 2020 | 2021 | 2022 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2020-2022 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 6,189.8 | 0.0 | 2,333.9 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| Asian Development Bank | 6,189.8 | 0.0 | 2,333.9 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 6,189.8 | 0.0 | 2,333.9 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: